**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ ១៧៥ ដ.ន.ស./ប្រក.

# ប្រកាស

## ស្តីពី

## បែបបទនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រវាស់វែង

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងលើការវាស់វែងនិងការផលិតផែនទី និងលើអាជីវកម្មវាស់វែងនិងការផលិតផែនទី
- បានឃើញប្រកាសលេខ ២០០ ដនស.ប្រក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែង
- យោងតាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់



អាសយដ្ឋាន៖ ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ ..**

ប្រកាសនេះមានគោលបំណង ៖

- ធានាប្រសិទ្ធភាពនៃការរៀបចំដែនការរៀបចំដែនដី នគរូបនីយកម្ម និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ
- ធានាភាពជាក់លាក់នៃលទ្ធផលការងារវាស់វែងនិងផលិតផែនទី
- ធានាប្រសិទ្ធភាពនៃការគ្រប់គ្រងការវាស់វែងនិងការផលិតផែនទី
- បង្ការនិងទប់ស្កាត់ការផ្សព្វផ្សាយ ការប្រើប្រាស់ជាសាធារណៈនូវផែនទី និងទិន្នន័យវាស់វែងដែលមិនត្រឹមត្រូវ និងគ្មានការអនុញ្ញាត។

**ប្រការ២ ..**

ប្រកាសនេះមានគោលដៅ ៖

- កំណត់កម្រិតវិញ្ញាបនបត្រវាស់វែងសម្រាប់អ្នកវាស់វែង
- កំណត់បែបបទនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រវាស់វែង។

**ប្រការ៣ ..**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះរូបវន្តបុគ្គលដែលធ្វើសកម្មភាពវាស់វែង និង/ឬផលិតផែនទី នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤ ..**

វាក្យសព្ទបច្ចេកទេសដែលប្រើក្នុងប្រកាសនេះមានដូចខាងក្រោម ៖

- **វិញ្ញាបនបត្រវាស់វែង** សំដៅដល់លិខិតទទួលស្គាល់សមត្ថភាពវាស់វែងរបស់រូបវន្តបុគ្គលដែលចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- **អ្នកវាស់វែងអាស៊ាន** សំដៅដល់អ្នកវាស់វែងនៃបណ្តារដ្ឋជាសមាជិកអាស៊ានដែលទទួលបានការវាយតម្លៃគុណវុឌ្ឍិនិងបទពិសោធន៍ដោយអនុលោមតាមអាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសសាមី ហើយបានចុះបញ្ជីនៅគណៈកម្មាធិការអាជ្ញាធរមានសមត្ថកិច្ចអាស៊ាន។

## ជំពូកទី២
## គោលការណ៍នៃការវាស់វែង

**ប្រការ៥ ..**

រូបវន្តបុគ្គលដែលអាចធ្វើការវាស់វែងបាន ត្រូវមានវិញ្ញាបនបត្រវាស់វែងផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

វិញ្ញាបនបត្រវាស់វែងអាចផ្តល់ជូនមន្ត្រីសាធារណៈដែលកំពុងបម្រើការក្នុងក្រសួង ស្ថាប័នរដ្ឋ និងរូបវន្តបុគ្គលឯកជន។

អ្នកវាស់វែងអាស៊ាន អាចបំពេញមុខងារជាអ្នកវាស់វែងនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយមិនតម្រូវឱ្យមានវិញ្ញាបនបត្រវាស់វែងឡើយ។

ជនបរទេសក្រៅពីអ្នកវាស់វែងអាស៊ាន ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រវាស់វែងនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ទើបអាចធ្វើការវាស់វែងនៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន។

**ប្រការ៦ ..**

រូបវន្តបុគ្គលដែលទទួលបានវិញ្ញាបនបត្រវាស់វែង មាននីតិសម្បទាដូចខាងក្រោម ៖

- អនុវត្តការងារវាស់វែងជូនក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចវាស់វែង
- បំពេញមុខងារជានាយកបច្ចេកទេស ឬជាអ្នកបច្ចេកទេសនៃក្រុមហ៊ុនប្រកបអាជីវកម្មវាស់វែង
- ចូលជាសមាជិកសមាគមអ្នកវាស់វែង។

**ប្រការ៧ ..**

រូបវន្តបុគ្គលដែលទទួលបានវិញ្ញាបនបត្រវាស់វែង ត្រូវ ៖

- អនុវត្តការងារស្របតាមស្តង់ដាក្នុងការវាស់វែងនិងការផលិតផែនទី
- ប្រតិបត្តិតាមក្រមសីលធម៌វិជ្ជាជីវៈអ្នកវាស់វែង
- ទទួលការបណ្តុះបណ្តាលលើការងារវាស់វែងដែលរៀបចំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- អនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងការណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៨ ..**

ការស្នើសុំវិញ្ញាបនបត្រវាស់វែង ត្រូវបង់កម្រៃសេវាសាធារណៈជូនរដ្ឋ ស្របតាមប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី៣
## កម្រិតនៃវិញ្ញាបនបត្រវាស់វែង

**ប្រការ៩ ..**

វិញ្ញាបនបត្រវាស់វែងមាន៣(បី)កម្រិត ដូចខាងក្រោម ៖

- **វិញ្ញាបនបត្រវាស់វែងកម្រិត "ក"** : សម្រាប់ផ្តល់ជូនរូបវន្តបុគ្គលដែលមានសញ្ញាបត្រវាស់វែងកម្រិតឧត្តម ឬកម្រិតប្រហាក់ប្រហែល និងមានបទពិសោធន៍ការងារក្នុងមុខជំនាញវាស់វែងយ៉ាងតិច២(ពីរ)ឆ្នាំ
- **វិញ្ញាបនបត្រវាស់វែងកម្រិត "ខ"** : សម្រាប់ផ្តល់ជូនរូបវន្តបុគ្គលដែលមានសញ្ញាបត្រវាស់វែងកម្រិតមធ្យម ឬកម្រិតប្រហាក់ប្រហែល និងមានបទពិសោធន៍ការងារក្នុងមុខជំនាញវាស់វែងយ៉ាងតិច២(ពីរ)ឆ្នាំ
- **វិញ្ញាបនបត្រវាស់វែងកម្រិត "គ"** : សម្រាប់ផ្តល់ជូនរូបវន្តបុគ្គលដែលមានសញ្ញាបត្រ ឬវិញ្ញាបនបត្រវាស់វែងកម្រិតបឋម និងមានបទពិសោធន៍ការងារក្នុងមុខជំនាញវាស់វែងយ៉ាងតិច២(ពីរ)ឆ្នាំ។

**ប្រការ១០ ..**

វិញ្ញាបនបត្រវាស់វែង មានសុពលភាពរយៈពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រ និងអាចសុំបន្តបាន។

ការស្នើសុំបន្តវិញ្ញាបនបត្រវាស់វែងត្រូវធ្វើឡើងក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ មុនពេលផុតកំណត់សុពលភាព។

## ជំពូកទី៤
## សំណុំឯកសារស្នើសុំវិញ្ញាបនបត្រវាស់វែង

**ប្រការ១១ ..**

សំណុំឯកសារស្នើសុំវិញ្ញាបនបត្រវាស់វែង មានដូចខាងក្រោម ៖

| | |
|---|---|
| - ពាក្យស្នើសុំវិញ្ញាបនបត្រវាស់វែង | ចំនួន០២ច្បាប់ |
| - ប្រវត្តិរូបសង្ខេបរបស់អ្នកដាក់ពាក្យស្នើសុំ | ចំនួន០២ច្បាប់ |
| - អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែននិងទិដ្ឋាការរបស់អ្នកដាក់ពាក្យស្នើសុំ(ថតចម្លង) | ចំនួន០២ច្បាប់ |
| - សញ្ញាបត្រ ឬវិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ការសិក្សា(ថតចម្លង) | ចំនួន០២ច្បាប់ |

- លិខិតបញ្ជាក់ពីបទពិសោធន៍ការងារវាស់វែង ឬលិខិតបញ្ជាក់សមត្ថភាពវាស់វែង ចំនួន០២ច្បាប់
- រូបថតអ្នកដាក់ពាក្យស្នើសុំ ទំហំ (៤x៦) ចំនួន០២សន្លឹក

រាល់ឯកសារថតចម្លងត្រូវធ្វើនីត្យានុកូលកម្មដោយអាជ្ញាធរមានសមត្ថកិច្ច ឬមន្ទីរសារការី។

គំរូទម្រង់សំណុំឯកសារស្នើសុំវិញ្ញាបនបត្រវាស់វែង ជាឧបសម្ព័ន្ធទី១នៃប្រកាសនេះ។

## ជំពូកទី៥
## នីតិវិធីនៃការពិនិត្យសម្រេចលើពាក្យស្នើសុំវិញ្ញាបនបត្រវាស់វែង

**ប្រការ១២ ..**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃ នៃថ្ងៃធ្វើការ ក្នុងការពិនិត្យ និងសម្រេចផ្តល់ ឬមិនផ្តល់វិញ្ញាបនបត្រវាស់វែង គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារពេញលេញនិងត្រឹមត្រូវ។

**ប្រការ១៣ ..**

សំណុំឯកសារស្នើសុំវិញ្ញាបនបត្រវាស់វែង ត្រូវដាក់នៅច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចេញបង្កាន់ដៃទទួលពាក្យស្នើសុំនៅពេលទទួលបានសំណុំឯកសារស្នើសុំពេញលេញនិងត្រឹមត្រូវ។

បន្ទាប់ពីទទួលបានសំណុំឯកសារស្នើសុំ ច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបញ្ជូនសំណុំឯកសារនេះទៅលេខាធិការដ្ឋាននៃគណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែង ក្នុងរយៈពេលយ៉ាងយូរ២(ពីរ)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។

គណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែង ត្រូវពិនិត្យនិងវាយតម្លៃទទួលស្គាល់សមត្ថភាពវាស់វែង និងលើកសំណើជូនរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងរយៈពេលយ៉ាងយូរ២៤(ម្ភៃបួន)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលសំណុំឯកសារ ដើម្បីសម្រេចផ្តល់និងចុះហត្ថលេខាលើវិញ្ញាបនបត្រវាស់វែង។

គណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែង ត្រូវបញ្ជូនវិញ្ញាបនបត្រវាស់វែងនិងសំណុំឯកសារពាក់ព័ន្ធផ្សេងទៀត ទៅច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងរយៈពេលយ៉ាងយូរ២(ពីរ)ថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីប្រគល់ជូនម្ចាស់សំណើ។

ច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំឯកសារក្នុងរយៈពេលយ៉ាងយូរ២(ពីរ)ថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីប្រគល់ជូនម្ចាស់សំណើ។

គំរូទម្រង់ប្រកាសស្តីពីការផ្តល់វិញ្ញាបនបត្រវាស់វែងនិងគំរូទម្រង់វិញ្ញាបនបត្រវាស់វែង ជាឧបសម្ព័ន្ធទី២នៃប្រកាសនេះ។

## ជំពូកទី៦
## ការព្យួរនិងការដកហូតវិញ្ញាបនបត្រវាស់វែង

**ប្រការ១៤ ..**

នៅពេលទទួលបានព័ត៌មាន ឬពាក្យបណ្តឹងអំពីការប្រព្រឹត្តល្មើសនឹងគោលការណ៍នៃការវាស់វែងដោយអ្នកមានវិញ្ញាបនបត្រវាស់វែង គណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែង ត្រូវធ្វើការស៊ើបអង្កេតលើការប្រព្រឹត្តអំពើល្មើសនោះ។

ក្នុងករណីអ្នកវាស់វែងមិនបានបំពេញតាមស្តង់ដានិងបច្ចេកទេសនៃការវាស់វែង គណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែង ត្រូវលើកសំណើជូនរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីចេញលិខិតព្រមានជាលាយលក្ខណ៍អក្សរ។

ក្នុងករណីអ្នកវាស់វែងមិនអនុវត្តតាមការណែនាំដូចមានចែងក្នុងលិខិតព្រមានជាលាយលក្ខណ៍អក្សរក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃគិតចាប់ពីថ្ងៃចេញលិខិតព្រមាន គណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែងត្រូវលើកសំណើជូនរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីចេញសេចក្តីសម្រេចព្យួរវិញ្ញាបនបត្រវាស់វែងជាបណ្តោះអាសន្នក្នុងរយៈពេលយ៉ាងយូរ៩០(កៅសិប)ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចព្យួរ។

ក្នុងករណីអ្នកវាស់វែងអនុវត្តតាមការណែនាំដូចមានចែងក្នុងលិខិតព្រមានក្នុងរយៈពេលនៃការព្យួរ គណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែង ត្រូវលើកសំណើជូនរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីចេញសេចក្តីសម្រេចលុបចោលការព្យួរវិញ្ញាបនបត្រវាស់វែង។

ក្នុងករណីអ្នកវាស់វែងមិនអនុវត្តតាមការណែនាំដូចមានចែងក្នុងលិខិតព្រមានក្នុងរយៈពេលនៃការព្យួរ គណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែង ត្រូវលើកសំណើជូនរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីចេញប្រកាសស្តីពីការដកហូតវិញ្ញាបនបត្រវាស់វែង។

គំរូទម្រង់ប្រកាសស្តីពីការដកហូតវិញ្ញាបនបត្រវាស់វែង ជាឧបសម្ព័ន្ធទី៣នៃប្រកាសនេះ។

**ប្រការ១៥ ..**

ក្នុងអំឡុងពេលនៃការព្យួរវិញ្ញាបនបត្រវាស់វែង អ្នកវាស់វែងត្រូវបាត់បង់នីតិសម្បទាដូចមានចែងក្នុងប្រការ៦ នៃប្រកាសនេះ។

## ជំពូកទី៧

## ទណ្ឌកម្ម

**ប្រការ១៦ ..**

អ្នកវាស់វែងណាដែលមិនគោរពតាមបទប្បញ្ញត្តិ ស្តង់ដា និងបច្ចេកទេសនៃការវាស់វែង ត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងជំពូកទី៧នៃអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងលើការវាស់វែងនិងការផលិតផែនទី និងលើអាជីវកម្មវាស់វែងនិងការផលិតផែនទី។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**ប្រការ១៧ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៨ ..**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន គណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែង និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៩កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

ជា សុផារ៉ា

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យ **សម្តេចតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៨ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធ៤ នៃប្រកាសលេខ ...១៧៥ ដនស/ប្រក...... ចុះថ្ងៃទី ០៥...... ខែ ធ្នូ............ឆ្នាំ២០១៩**
**ស្តីពីបែបបទនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រវាស់វែង**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យស្នើសុំវិញ្ញាបនបត្រវាស់វែង

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.............................ភេទ..........ថ្ងៃខែឆ្នាំកំណើត......................
កាន់អត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែនលេខ...................សញ្ជាតិ.........ប្រពន្ធ/ប្តីឈ្មោះ............
ថ្ងៃខែឆ្នាំកំណើត..........................កាន់អត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែនលេខ........................
សញ្ជាតិ..........ទីលំនៅបច្ចុប្បន្នផ្ទះលេខ...........ផ្លូវ............ភូមិ............ឃុំ/សង្កាត់..............
ក្រុង/ស្រុក/ខណ្ឌ....................រាជធានី/ខេត្ត........................ ។

**សូមគោរពជូន**
**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**តាមរយៈ**÷ -លោកប្រធានច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-គណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែង

**កម្មវត្ថុ** ÷ សំណើសុំផ្តល់វិញ្ញាបនបត្រវាស់វែង កម្រិត......................

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាផ្តល់វិញ្ញាបនបត្រវាស់វែងឱ្យខ្ញុំបាទ/នាងខ្ញុំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

<u>សូមគោរពជូនភ្ជាប់ជាមួយនូវ÷</u>

| | |
|---|---|
| -ប្រវត្តិរូបសង្ខេប | ចំនួន០២ច្បាប់ |
| -ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែននិងទិដ្ឋាការ | ចំនួន០២ច្បាប់ |
| -ច្បាប់ចម្លងសញ្ញាបត្រ ឬវិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ការសិក្សា | ចំនួន០២ច្បាប់ |
| -លិខិតបញ្ជាក់បទពិសោធន៍ការងារវាស់វែង ឬលិខិតបញ្ជាក់សមត្ថភាពវាស់វែង | ចំនួន០២ច្បាប់ |
| -រូបថតអ្នកដាក់ពាក្យស្នើសុំ ទំហំ ៤x៦ | ចំនួន០២សន្លឹក |

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦...
ធ្វើនៅ.......................ថ្ងៃទី ខែ ឆ្នាំ២០....
**ហត្ថលេខា ឬស្នាមមេដៃស្តាំអ្នកស្នើសុំ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

| |
|---|
| **រូបថត** |
| 4x6 |

# ប្រវត្តិរូបសង្ខេប

## ១. ព័ត៌មានផ្ទាល់ខ្លួន

នាម និងគោត្តនាម : ............................ អក្សរឡាតាំង.............................

សញ្ជាតិ : ............................ ថ្ងៃខែឆ្នាំកំណើត.........................

ទីកន្លែងកំណើត : ................................................................................

អត្តសញ្ញាណប័ណ្ណលេខ : .................................. ចុះថ្ងៃទី......... ខែ......... ឆ្នាំ........

លិខិតឆ្លងដែនលេខ : .................................. ចុះថ្ងៃទី........ ខែ........ ឆ្នាំ.........

អាសយដ្ឋានបច្ចុប្បន្ន : ................................................................................

ទូរសព្ទលេខ : .................................. អ៊ីមែល ............................

ឈ្មោះអង្គភាពបម្រើការងារ : .................................. តួនាទី.............................

អាសយដ្ឋានអង្គភាពការងារ : ................................................................................

## ២. ស្ថានភាពគ្រួសារ

ប្តី ឬប្រពន្ធឈ្មោះ : ....................... ឆ្នាំកំណើត.................... មុខរបរ.........

កូនឈ្មោះ : ....................... ភេទ..... ឆ្នាំកំណើត.......... មុខរបរ.........

: ....................... ភេទ..... ឆ្នាំកំណើត.......... មុខរបរ.........

: ....................... ភេទ..... ឆ្នាំកំណើត.......... មុខរបរ.........

: ....................... ភេទ..... ឆ្នាំកំណើត.......... មុខរបរ.........

## ៣. ការបណ្តុះបណ្តាលបន្ត

| ល.រ | ជំនាញឯកទេស | ស្ថាប័នបណ្តុះបណ្តាល | រយៈពេល |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |

### ៤. ជំនាញផ្សេងៗ

| ល.រ | មុខជំនាញ | ចិញ្ញាបនបត្រ/សញ្ញាបត្រ | រយៈពេល | ឆ្នាំបញ្ចប់ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |

### ៥. បទពិសោធន៍ការងារ

| ពីឆ្នាំណា ដល់ឆ្នាំណា | អង្គភាពបម្រើការងារ | តួនាទី |
|---|---|---|
| | | |
| | | |
| | | |
| | | |

*<u>បញ្ជាក់÷</u> បេក្ខជនអាចបន្ថែមទំព័រ ប្រសិនបើមានតម្រូវការសរសេរបន្ថែម។*

ខ្ញុំបាទ/ នាងខ្ញុំសូមធានាអះអាងថា ព័ត៌មានក្នុងប្រវត្តិរូបខាងលើនេះពិតជាត្រឹមត្រូវពិតប្រាកដមែន។ ក្នុងករណីខុសពីការពិតខ្ញុំបាទ/ នាងខ្ញុំ សូមទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦.....

ធ្វើនៅ................... ថ្ងៃទី ខែ ឆ្នាំ២០......

**ហត្ថលេខា និងឈ្មោះ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# លិខិតបញ្ជាក់បទពិសោធន៍ការងារវាស់វែង[១]

ខ្ញុំបាទ/ នាងខ្ញុំឈ្មោះ.................................... ភេទ........... ថ្ងៃខែឆ្នាំកំណើត...................
កាន់អត្តសញ្ញាណបណ្ណ/ លិខិតឆ្លងដែនលេខ.......................... សញ្ជាតិ............... ទីលំនៅបច្ចុប្បន្ន
ផ្ទះលេខ........... ផ្លូវ............ ភូមិ................. ឃុំ/ សង្កាត់................. ក្រុង/ ស្រុក/ ខណ្ឌ..............
រាជធានី/ ខេត្ត............................... (អ្នកស្នើសុំ)។

ខ្ញុំបាទ/ នាងខ្ញុំឈ្មោះ............................... ភេទ........... ថ្ងៃខែឆ្នាំកំណើត........................
កាន់អត្តសញ្ញាណបណ្ណ/ លិខិតឆ្លងដែនលេខ.......................... សញ្ជាតិ................. លំនៅបច្ចុប្បន្ន
ផ្ទះលេខ......... ផ្លូវ............ ភូមិ............. ឃុំ/ សង្កាត់...................... ក្រុង/ ស្រុក/ ខណ្ឌ.................
រាជធានី/ ខេត្ត....................... អត្តលេខ .............. លេខវិញ្ញាបនបត្រវាស់វែង .........................
ថ្ងៃខែឆ្នាំចេញវិញ្ញាបនបត្រវាស់វែង .............................. ទូរសព្ទ ..........................................
អ៊ីម៉ែល........................................................ (អ្នកដឹកនាំ)។

**១.សូមបំពេញក្នុងតារាងខាងក្រោមនូវព័ត៌មានអំពីពេលវេលា ដែលអ្នកស្នើសុំស្ថិតក្រោមការដឹកនាំរបស់អ្នក**

| ពី (ខែ/ឆ្នាំ) | ដល់ (ខែ/ ឆ្នាំ) | រយៈពេលចំនួន (ខែ) |
|---|---|---|
| | | |
| | | |
| | | |
| | | |
| សរុបរយៈពេលចំនួន (ខែ) | | |

---

[១] ទម្រង់លិខិតនេះ ត្រូវបំពេញដោយអ្នកវាស់វែង ដែលជាអ្នកដឹកនាំការងាររបស់អ្នកស្នើសុំវិញ្ញាបនបត្រវាស់វែង និងត្រូវភ្ជាប់ជាមួយសំណុំឯកសារស្នើសុំវិញ្ញាបនបត្រវាស់វែង

**២. សូមបំពេញតារាងខាងក្រោមនូវព័ត៌មានអំពីសកម្មភាពវាស់វែងរបស់អ្នកស្នើសុំក្នុងអំឡុងពេលស្ថិតក្រោមការដឹកនាំរបស់អ្នក**

| ការទទួលខុសត្រូវរបស់អ្នកស្នើសុំ[២] | បទពិសោធន៍លើដីជាក់ស្តែង (ខែ) | បទពិសោធន៍ក្នុងការិយាល័យ (ខែ) |
|---|---|---|
| ពុំមានការទទួលខុសត្រូវ | | |
| ទទួលខុសត្រូវក្នុងការវាស់វែងសុរិយោដី | | |
| ទទួលខុសត្រូវក្នុងការវាស់វែងគ្រប់ប្រភេទរួមទាំងការវាស់វែងសុរិយោដី | | |
| សរុបបទពិសោធន៍ (ខែ) | | |

**៣. សូមគូសក្នុងប្រអប់ដើម្បីបំពេញនូវការប្រកាសរបស់អ្នកស្នើសុំក្នុងការងារវាស់វែងនៅក្នុងតារាងខាងក្រោម**

| តើអ្នកស្នើសុំបានបំពេញដោយសមស្របចំពោះប្រភេទការងារវាស់វែងណាមួយដូចខាងក្រោមនៅពេលដែលស្ថិតនៅក្រោមការដឹកនាំរបស់អ្នក | |
|---|---|
| **បទពិសោធន៍ការងារវាស់វែងដីជាក់ស្តែង** | **ចម្លើយ** |
| ការវាស់វែងបណ្តាញប្រឹថពីវិភាគប្លង់រាប និងកម្ពស់ | ☐ បាទ/ចាស ☐ ទេ |
| ការវាស់វែងសុរិយោដី | ☐ បាទ / ចាស ☐ ទេ |
| ការវាស់វែងប្រឹថពីវិភាគ | ☐ បាទ/ចាស ☐ ទេ |
| ការវាស់វែងឋានលេខា | ☐ បាទ / ចាស ☐ ទេ |
| ការវាស់វែងក្នុងគោលដៅសំណង់ហេដ្ឋារចនាសម្ព័ន្ធរបវត្ត | ☐ បាទ/ចាស ☐ ទេ |

[២] ការទទួលខុសត្រូវ គឺអ្នកវាស់វែងស្ថិតក្នុងតួនាទីជាអ្នកដឹកនាំក្នុងសកម្មភាពវាស់វែងណាមួយ

| បទពិសោធន៍នៅក្នុងការិយាល័យ | ចម្លើយ |
| --- | --- |
| ការបញ្ចូល និងគណនាទិន្នន័យវាស់វែង | ☐ បាទ/ចាស ☐ ទេ |
| ការតាក់តែងគំនូសប្លង់ ផែនទីតាមទិន្នន័យវាស់វែង | ☐ បាទ/ចាស ☐ ទេ |
| ការតាក់តែងផែនទីតាមទិន្នន័យផែនទីគោល | ☐ បាទ/ចាស ☐ ទេ |

**៤.ការធានាអះអាង**

ខ្ញុំបាទ/នាងខ្ញុំសូមធានាអះអាងថា រាល់ព័ត៌មានទាំងអស់ដែលខ្ញុំបានសរសេរក្នុងទម្រង់នេះពិតជាត្រឹមត្រូវពិតប្រាកដមែន។ ក្នុងករណីខុសពីការពិតខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវចំពោះមុខច្បាប់។

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦...

ធ្វើនៅ.......................ថ្ងៃទី ខែ ឆ្នាំ២០......

**ហត្ថលេខា និងឈ្មោះ (អ្នកដឹកនាំ)**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ:..........................................................

# ប្រកាស
# ស្តីពី
# ការផ្តល់វិញ្ញាបនបត្រវាស់វែង

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨ /៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម ០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងលើការវាស់វែងនិងការផលិតផែនទី និងលើអាជីវកម្មវាស់វែងនិងការផលិតផែនទី
- បានឃើញប្រកាសលេខ ២០០ ដនស.ប្រក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែង
- យោងតាមសំណើរបស់សាមីខ្លួន

## សម្រេច

**ប្រការ១ .**_

ត្រូវបានផ្តល់វិញ្ញាបនបត្រវាស់វែង ជូនលោក/ លោកស្រី .............................. ភេទ ....... ថ្ងៃខែឆ្នាំកំណើត ......................... សញ្ជាតិ .............. កាន់អត្តសញ្ញាណបណ្ណ/ លិខិតឆ្លងដែនលេខ .................... មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ........... ផ្លូវលេខ ......... ឃុំ/ សង្កាត់ .......... ក្រុង/ ស្រុក/ ខណ្ឌ .......... រាជធានី/ ខេត្ត ............ ក្នុងកម្រិត ............ តទៅនេះហៅថា “**អ្នកកាន់វិញ្ញាបនបត្រវាស់វែង**”។


ទូរសព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

**ប្រការ២ ._**

វិញ្ញាបនបត្រវាស់វែង មានសុពលភាពរយៈពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រ និង អាចសុំបន្តបាន។

ការស្នើសុំបន្តវិញ្ញាបនបត្រវាស់វែងត្រូវធ្វើឡើងក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ មុនពេលផុត កំណត់សុពលភាព។

**ប្រការ៣ ._**

អ្នកកាន់វិញ្ញាបនបត្រវាស់វែង មានកាតព្វកិច្ចដូចខាងក្រោម ÷

- អនុវត្តការងារស្របតាមស្តង់ដាក្នុងការវាស់វែងនិងការផលិតផែនទី
- ប្រតិបត្តិតាមក្រមសីលធម៌វិជ្ជាជីវៈអ្នកវាស់វែង
- ទទួលការបណ្តុះបណ្តាលលើការងារវាស់វែងដែលរៀបចំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- អនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងការណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤ ._**

អ្នកវាស់វែងណាដែលមិនគោរពតាមបទប្បញ្ញត្តិ ស្តង់ដា និងបច្ចេកទេសនៃការវាស់វែង ត្រូវ ទទួលទណ្ឌកម្មដូចមានចែងក្នុងជំពូកទី៧នៃអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងលើការវាស់វែងនិងការផលិតផែនទី និងលើអាជីវកម្មវាស់វែងនិងការ ផលិតផែនទី។

**ប្រការ៥ ._**

ប្រកាសនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦_

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០...

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

<u>កន្លែងទទួល:</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- សាមីខ្លួន ដូចប្រការ១
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
MINISTRY OF LAND MANAGEMENT, URBAN PLANNING AND CONSTRUCTION

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

លេខ/Nº: ....................................

# វិញ្ញាបនបត្រវាស់វែង
# CERTIFICATE FOR SURVEYING

4 x 6

គោត្តនាម និងនាម:.................................. ភេទ............. ថ្ងៃខែឆ្នាំកំណើត........................ សញ្ជាតិ:..............
SURNAME AND NAME:.................................. SEX................ DATE OF BIRTH........................... NATIONALITY:........
លេខបញ្ជី:...............................................................................................................
REGISTRATION NUMBER:...............................................................................................
កាលបរិច្ឆេទចុះបញ្ជី:.....................................................................................................
REGISTRATION DATE:...................................................................................................
**អ្នកវាស់វែង** កម្រិត....................................................................................................
SURVEYOR OF LEVEL:...................................................................................................
សុពលភាព: ពីថ្ងៃទី............ខែ............ឆ្នាំ............ដល់ថ្ងៃទី............ខែ............ឆ្នាំ.................................
VALIDITY:.......................................................................................TO ...................................

អ្នកកាន់វិញ្ញាបនបត្រនេះត្រូវគោរពច្បាប់និងបទបញ្ញាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។
THE HOLDER OF THE CERTIFICATE SHALL OBSERVE AND COMPLY WITH LAWS, RULES AND REGULATIONS OF THE KINGDOM OF CAMBODIA.

ថ្ងៃ............................ ខែ...............ឆ្នាំ................. ព.ស.................
រាជធានីភ្នំពេញ ថ្ងៃទី ...............ខែ ................ ឆ្នាំ ...................
PHNOM PENH, .......................................................

រដ្ឋមន្ត្រី
MINISTER

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ:.....................................................

# ប្រកាស

## ស្តីពី

## ការដកហូតវិញ្ញាបនបត្រវាស់វែង

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម ០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងលើការវាស់វែងនិងការផលិតផែនទី និងលើអាជីវកម្មវាស់វែងនិងការផលិតផែនទី
- បានឃើញប្រកាសលេខ ២០០ ដនស.ប្រក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែង
- បានឃើញប្រកាសលេខ .................................................. ចុះថ្ងៃទី ............... ខែ............ ឆ្នាំ២០...... ស្តីពីការផ្តល់វិញ្ញាបនបត្រវាស់វែង
- យោងតាមសំណើរបស់គណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែង

### សម្រេច

**ប្រការ១ .-**

ត្រូវបានដកហូតវិញ្ញាបនបត្រវាស់វែង ពីលោក/លោកស្រី ........................... ភេទ........... ថ្ងៃខែឆ្នាំកំណើត ........................... សញ្ជាតិ ............... កាន់អត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែន

លេខ ......................... មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ..................... ផ្លូវលេខ ................ ឃុំ/ សង្កាត់ .................. ក្រុង/ ស្រុក/ ខណ្ឌ ................ រាជធានី/ ខេត្ត ............................. ក្នុងកម្រិត ....... ដែលហៅថា "**អ្នកកាន់វិញ្ញាបនបត្រវាស់វែង**" ដែលបានផ្ដល់ជូនវិញ្ញាបនបត្រវាស់វែង តាមប្រកាសលេខ .................................. ចុះថ្ងៃទី ........... ខែ ............ ឆ្នាំ២០ ...... ស្ដីពីការផ្ដល់វិញ្ញាបនបត្រវាស់វែង។

**ប្រការ២ . _**

រូបវន្តបុគ្គលដែលត្រូវបានដកហូតវិញ្ញាបនបត្រវាស់វែង ត្រូវបាត់បង់នីតិសម្បទា ÷

- ជាអ្នកវាស់វែង
- មិនអាចបំពេញមុខងារជានាយកបច្ចេកទេស ឬជាអ្នកបច្ចេកទេសនៃក្រុមហ៊ុនប្រកបអាជីវកម្មវាស់វែង
- មិនអាចចូលជាសមាជិកសមាគមអ្នកវាស់វែង។

**ប្រការ៣ . _**

បុគ្គលណាដែលមិនគោរពតាមបទប្បញ្ញត្តិ ស្ដង់ដា និងបច្ចេកទេសនៃការវាស់វែង ត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងជំពូកទី៧នៃអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្ដីពីការគ្រប់គ្រងលើការវាស់វែងនិងការផលិតផែនទី និងលើអាជីវកម្មវាស់វែងនិងការផលិតផែនទី។

**ប្រការ៤ . _**

ប្រកាសនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦_

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០...

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**កន្លែងទទួល:**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- សាមីខ្លួន ដូចប្រការ១
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ